N: 13-14

15-4-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ១៣_១៤ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

ក

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១១–៤–១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៤៩៧/១២ ស្តីពីការបង្កើតបណ្ឌិតសភា កងយោធពលខេមរភូមិន្ទ	៨៦៧
១១–៤–១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៤៩៧/១៣ តែងតាំងមុខងារ និង ប្រគល់ឋានន្តរសក្តិកិត្តិយស ជូននាយ ទាហានជាន់ខ្ពស់	៨៦៨
១១–៤–១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៤៩៧/១៤ តែងតាំងមុខងារ និង ប្រគល់ឋានន្តរសក្តិថ្នាក់ឧត្តមសេនិយត្រី ជូននាយទាហានជាន់ខ្ពស់	៨៧០

II- រាជរដ្ឋាភិបាល

១–អនុក្រឹត្យ

០៨–៤–១៩៩៧	អនុក្រឹត្យលេខ ៤២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៨៧១

III- ការិយាល័យក្រសួង

១–ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសអន្តរក្រសួង

០៩–៤–១៩៩៧	ប្រកាសលេខ ១២៩ សហវ.ប្រក ស្តីពីការបង្កើតរដ្ឋទេយ្យបុរេប្រទាននៅក្រសួងមហាផ្ទៃ«ផ្នែករដ្ឋបាល»	៨៧៣

០៩-៤-១៩៩៧ ប្រកាសលេខ ១៣១ សហវ.មក្រប ស្តីពីការបង្កើតរដ្ឋទេយ្យបុរេប្រទាននៅរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ៨៧៧

២—ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

១០-៤-១៩៩៧ ប្រកាសលេខ ១២៥ ពណគន.ប្រក ស្តីពីការប្រគល់ដីយានដ្ឋាន នៅសង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក ក្រុងភ្នំពេញ ជូនទៅ លោក ឈិត មាន ៨៧៩

៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

០៣-៤-១៩៩៧ ប្រកាសលេខ ៣៦៧ ផក.ប្រក អនុញ្ញាតអោយលោក សេង ឈី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងសិប្បកម្មផលិត ឥដ្ឋការ៉ូ ៨៨០
០៣-៤-១៩៩៧ ប្រកាសលេខ ៣៦៨ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ស៊ូ ជូហៀង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតឥដ្ឋ-ក្បឿង ៨៨១
០៧-៤-១៩៩៧ ប្រកាសលេខ ៣៧២ផក.ប្រក អនុញ្ញាតអោយលោក ជៀប ជិនឃុន ជនជាតិខ្មែរ សញ្ជាតិកម្ពុជាបើកដំណើរការសិប្បកម្មផលិតសំភារៈ ប្រើប្រាស់អំពីផ្លាស្ទិក ៨៨១

០៧-៤-១៩៩៧	ប្រកាសលេខ ៣៧៣ផក.ប្រក អនុញ្ញាតអោយលោក **ចុង ហាក់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងក្រឡឹងដែក	៨៨២
០៧-៤-១៩៩៧	ប្រកាសលេខ ៣៧៤ផក.ប្រក អនុញ្ញាតអោយលោក **ចាន់ ភាយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការឧស្សាហកម្មតូចផលិត ឧស្ម័នអុកស៊ីហ្សែន	៨៨២
០៧-៤-១៩៩៧	ប្រកាសលេខ ៣៧៥ផក.ប្រក អនុញ្ញាតអោយលោក **ទេស ឡេត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ	៨៨៣
០៧-៤-១៩៩៧	ប្រកាសលេខ ៣៧៦ ផក.ប្រក អនុញ្ញាតអោយលោក **ម៉ែន សាន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាបន្តដំណើរការឧស្សាហកម្មតូចផលិត សៀវភៅសរសេរ	៨៨៣
០៧-៤-១៩៩៧	ប្រកាសលេខ ៣៧៧ផក.ប្រក អនុញ្ញាតអោយលោក **ទង់ ណារិន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ២គ្រឿង កំលាំង ៨០-១២០សេះ	៨៨៤
០៧-៤-១៩៩៧	ប្រកាសលេខ ៣៧៨ផក.ប្រក អនុញ្ញាតអោយលោក **សុខ គង់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មកាត់ដេរសំលៀកបំពាក់	៨៨៤
០៧-៤-១៩៩៧	ប្រកាសលេខ ៣៨០ផក.ប្រក អនុញ្ញាតអោយលោក **ឈាង ម៉ាច** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មកែច្នៃទឹកត្រី និងទឹកក្រឿង	៨៨៥
០៩-៤-១៩៩៧	ប្រកាសលេខ ៣៨២ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនផលិតម្សៅ ដំឡូងមី-ចំការ (FLOUR MANUFACTURING	

	CO. LTD) តំណាងដោយលោក **កែវ ទុន្នី** បង្កើតរោងចក្រផលិតម្សៅ ជំឡូងមី	៨៨៦
០៩–៤–១៩៩៧	ប្រកាសលេខ ៣៨៣ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនសុភី ខេមបូឌា (C.P CAMBODIA CO. LTD) តំណាងដោយលោក ANAN ATHI-GAPANICH ជនជាតិថៃ បង្កើតរោងចក្រផលិតចំណីសត្វ	៨៨៦
១០–៤–១៩៩៧	ប្រកាសលេខ ៣៨៤ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **គ្រួយ លៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ផ្ទេរភារកិច្ចគ្រប់គ្រងម៉ាស៊ីកិនស្រូវជូន លោក **យូ សារមេត** វិញ	៨៨៧
១០–៤–១៩៩៧	ប្រកាសលេខ ៣៨៥ ផក.ប្រក អនុញ្ញាតអោយលោក **ឆូ ហួត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតនំផ្អែម ឃីហោ «សេង ហួត»	៨៨៨

៤— ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

០៤–៤–១៩៩៧	ប្រកាសលេខ ០៩៩/៩៧ពម.ប្រក អនុញ្ញាតជូនលោក **ហ៊ី មៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តបើកអាជីវកម្មរោងពុម្ព ដែលមានឈ្មោះ «រស្មីអង្គរ»	៨៨៩
០៧–៤–១៩៩៧	ប្រកាសលេខ ១០១/៩៧ អនុញ្ញាតអោយ លោក **ជឹង សានឌី** បើកអាជីវកម្មទូរទស្សន៍រលកធាតុអាកាសប្រព័ន្ធ MMDS	៨៩០

៥–ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាសរួម

០១–៤–១៩៩៧ ប្រកាសលេខ ១៤៧ប្រក.សក ស្តីពីពន្ធលើការធ្វើដំណើរ នៅព្រលានយន្តហោះអន្តរជាតិពោធិចិនតុង ៨៩១

៦–ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១–សេចក្តីសំរេច

០២–៤–១៩៩៧ សេចក្តីសំរេចលេខ ១៥៩ សសរ.កសក ស្តីពីថ្លៃលក់ ឧបករណ៍សំភារៈកសិកម្ម ៨៩៣

២–ប្រកាស

០៩–៤–១៩៩៧ ប្រកាសលេខ ១៦៣ កសក ស្តីពីការអនុញ្ញាតអោយ បង្កើតកសិដ្ឋានចិញ្ចឹមសត្វ ៨៩៦

៧–ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

០៣–៤–១៩៩៧ ប្រកាសលេខ ២៦២ អយក.ប្រក ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា «ភូមិចាចុង» មកជាសាលាបឋម សិក្សា «ហ៊ុនសែន ចាចុង» ៨៩៩
០៣–៤–១៩៩៧ ប្រកាសលេខ ២៦៣ អយក.ប្រក ស្តីពីការអនុញ្ញាត អោយបើកសាលាបឋមសិក្សា «សម្តេចឪ សម្តេចម៉ែ» ក្នុងដែនទីសិក្សាខេត្ត ស្ទឹងត្រែង ៩០០
០៨–៤–១៩៩៧ ប្រកាសលេខ ២៧២ អយក.ប្រក ស្តីពីការអនុញ្ញាត អោយបោះពុម្ពសៀវភៅជីវវិទ្យា«សំរាប់សិស្សថ្នាក់ទី៨» ៩០២

០៨-៤-១៩៩៧ ប្រកាសលេខ ២៧៣អយក.ប្រក ស្ដីពីការអនុញ្ញាត បើកអនុវិទ្យាល័យ «ព្រៃកលីវ» ក្នុងឃុំរកាអារ ស្រុក កងមាស ខេត្តកំពង់ចាម ៩០៣

៨—នីស្ដីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

០៣-៤-១៩៩៧ ប្រកាសលេខ ៨៧ ប្រក.វវស.បុ ស្ដីពីការទទួលស្គាល់ លទ្ធផលនៃ ការប្រឡងបញ្ចប់បរិញ្ញាបត្រសិល្បៈ ផ្នែក បុរាណវិទ្យាជំនាន់ទី III ឆ្នាំ សិក្សា ១៩៩៥-៩៦ ៩០៥
០៧-៤-១៩៩៧ ប្រកាសលេខ ៨៨ ប្រក.វវស.បុ ស្ដីពីការទទួលស្គាល់ ជាវិរៈសិល្បករ សិល្បការិនី ប្រចាំឆ្នាំ ១៩៩៦-៩៧ ៩០៨

៩—រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្ដីសំរេច

០៨-៤-១៩៩៧ សេចក្ដីសំរេចលេខ ១៩៨ សសរ.មស.ក្រខ ស្ដីពីការ បែងចែកសិស្ស និស្សិត ចំនួន ១៨៣នាក់ ដែលទើប បញ្ចប់ការសិក្សាពីសាលាមធ្យមសិក្សាកសិកម្មព្រែកលៀប ៩០៩
០៨-៤-១៩៩៧ សេចក្ដីសំរេចលេខ ១៩៩ សសរ.មស.ក្រខ ស្ដីពីការបែង ចែកសិស្ស និស្សិត ចំនួន ១២នាក់ ដែលទើប បញ្ចប់ការ សិក្សាពីក្រៅប្រទេស ៩១៨

១០—នីស្ដីការក្រសួងធម្មការ និងសាសនា

សេចក្ដីសំរេច

០២-៤-១៩៩៧ សេចក្ដីសំរេចលេខ ៦៥/៩៧ កធស.នធ ស្ដីពីការទទួល ស្គាល់ពុទ្ធិកសមាគមខ្មែរ នៅកម្ពុជា ៩២១

០៤-៤-១៩៩៧	សេចក្តីសំរេចលេខ ៦៧/៩៧កធស.នធ ស្តីពីការអនុញ្ញាតអោយកសាងវត្តថ្មី	៩២២
០៤-៤-១៩៩៧	សេចក្តីសំរេចលេខ ៦៨/៩៧កធស អនុញ្ញាតអោយបើកស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ក្រុមសហព័ន្ធគ្រិស្តបរិស័ទខ្មែរ នៃព្រះវិហារ «ប្រកាសដំណឹង ល្អ ពីព្រះយេស៊ូគ្រិស្ត» នៅភូមិដូនហុង ឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប	៩២៣
០៤-៤-១៩៩៧	សេចក្តីសំរេចលេខ ៦៩/៩៧ កធស អនុញ្ញាតអោយបើកស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់នៃព្រះវិហារ «ប្រកាសដំណឹង ល្អពីព្រះយេស៊ូគ្រិស្ត»នៅភូមិសាលាកន្សែង ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្ត សៀមរាប	៩២៥
០៤-៤-១៩៩៧	សេចក្តីសំរេចលេខ ៧០/៩៧កធស អនុញ្ញាតអោយបើកស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ «ប្រកាសដំណឹងល្អពីព្រះយេស៊ូ គ្រិស្ត»នៅភូមិដីរឆ្នង ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប	៩២៧
០៤-៤-១៩៩៧	សេចក្តីសំរេចលេខ ៧១/៩៧ កធស អនុញ្ញាតអោយបើកស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ «ប្រកាសដំណឹងល្អពីព្រះយេស៊ូ គ្រិស្ត»នៅភូមិកន្ទ្រាំង ឃុំកន្ទ្រាំង ស្រុកប្រាសាទបាគង ខេត្តសៀមរាប	៩២៩
០៤-៤-១៩៩៧	សេចក្តីសំរេចលេខ ៧២/៩៧ កធស អនុញ្ញាតអោយបើកស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ «ប្រកាសដំណឹងល្អពីព្រះយេស៊ូគ្រិស្ត»នៅភូមិវាល ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប	៩៣០
០៨-៤-១៩៩៧	សេចក្តីសំរេចលេខ ៧៣/៩៧កធស អនុញ្ញាតអោយ	

	បើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់«ជីវិតថ្មីជប់ភរី» ឃុំជប់ភរី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ	៩៣២
០៨–៤–១៩៩៧	សេចក្តីសំរេចលេខ ៧៤/៩៧ កធស អនុញ្ញាតអោយបើកស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ «ជីវិតថ្មី ភូមិចំណាងទាក» ឃុំពាមមន្ទារ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង	៩៣៤
០៨–៤–១៩៩៧	សេចក្តីសំរេចលេខ ៧៥/៩៧ កធស អនុញ្ញាតអោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់«ជីវិតថ្មីប្រាសាទ»ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង	៩៣៥
០៨–៤–១៩៩៧	សេចក្តីសំរេចលេខ ៧៦/៩៧ កធស អនុញ្ញាតអោយបើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់«ក្រុមជំនុំព្រះគ្រិស្ត ព្រះអង្គសង្គ្រោះ» នៅភូមិល្វេងក្រោម ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ	៩៣៧
០៨–៤–១៩៩៧	សេចក្តីសំរេចលេខ ៧៧/៩៧ កធស អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ «ជីវិតថ្មី ភូមិអង្គស្វាយចេក» នៅភូមិអង្គស្វាយចេក ឃុំចារស្រុកព្រៃកប្បាស ខេត្តតាកែវ	៩៣៩
០៨–៤–១៩៩៧	សេចក្តីសំរេចលេខ ៧៨/៩៧ កធស អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់«ជីវិតថ្មីសំបួរ»នៅឃុំសំបួរ ស្រុកស្វាយទៀប ខេត្តស្វាយរៀង	៩៤០
០៨–៤–១៩៩៧	សេចក្តីសំរេចលេខ ៧៩/៩៧ កធស អនុញ្ញាតអោយបើកសាខាស្នាក់ ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ «កាតូលិក ខេត្តកំពង់ធំ»នៅ ភូមិកំពង់រទេះ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ	៩៤២

០៨-៤-១៩៩៧	សេចក្តីសំរេចលេខ ៨១/៩៧ កធស អនុញ្ញាតអោយបើកសាខាស្នាក់ ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ «ជីវិតថ្មី ភូមិឡូ៍២» នៅឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង	៩៤៤
១១-៤-១៩៩៧	សេចក្តីសំរេចលេខ ៨២/៩៧ កធស អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ «ជីវិតថ្មី ជើងព្រៃ» នៅឃុំសូទិប ស្រុកជើងព្រៃ ខេត្តកំពង់ចាម	៩៤៥
១១-៤-១៩៩៧	សេចក្តីសំរេចលេខ ៨៣/៩៧កធស អនុញ្ញាតអោយបើកសាខាស្នាក់ ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ «ជីវិតថ្មី ភូមិបឹងក្រទិប»នៅ ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង	៩៤៧
១១-៤-១៩៩៧	សេចក្តីសំរេចលេខ ៨៤/៩៧ កធស អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ «ជីវិតថ្មីព្រៃធំ»នៅឃុំព្រៃធំ ស្រុកកំពង់លាវ ខេត្តព្រៃវែង	៩៤៩
១១-៤-១៩៩៧	សេចក្តីសំរេចលេខ ៨៥/៩៧ កធស អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ «ជីវិតថ្មីព្រៃក្រាំង» នៅឃុំព្រៃពោរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង	៩៥០

* * * * *

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ ជស/រកត/០៤៩៧/១២

ស្តីពីការបង្កើតបណ្ឌិតសភា

កងយោធពលខេមរភូមិន្ទ

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងក្រឹត្យចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងសហអគ្គមេបញ្ជាការ នៃកំលាំងប្រដាប់អាវុធជាតិកម្ពុជា
- យោងក្រឹត្យចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និងអគ្គសេនាធិការនៃកងទ័ពជាតិកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទាំងពីរ និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបង្កើត បណ្ឌិតសភាយោធាដែលមានសញ្ញាសំគាល់ថា «**បណ្ឌិតសភាកងយោធពលខេមរភូមិន្ទ**» ស្ថិតនៅក្រោមការគ្រប់គ្រង បញ្ជាដឹកនាំផ្ទាល់របស់សហអគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា ២ : រចនាសម្ព័ន្ធចាត់តាំង និងតួនាទីភារកិច្ចរបស់បណ្ឌិតសភាកងយោធពលខេមរភូមិន្ទ អាស្រ័យដោយសហអគ្គមេបញ្ជាការកំណត់ ជាក់ស្តែង ។

មាត្រា ៣ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និងជាសហអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាមនិងតាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * * * *

ព្រះរាជក្រឹត្យ ជស/រកត/០៤៩៧/១៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទាំងពីរ និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងមុខងារ និងប្រគល់ឋានន្តរស័ក្តិ កិត្តិយស ជូននាយទាហានជាន់ខ្ពស់ ដែលមានរាយនាមដូចខាងក្រោមនេះ :

* **ថ្នាក់ឧត្តមសេនីយ៍ទោ :**

១- លោក **នី គន** ជាទីប្រឹក្សា ក្រសួងការពារជាតិ

២- លោក **សំ មិត** ជាទីប្រឹក្សា ក្រសួងការពារជាតិ

៣- លោក **មាស មុត** ជាទីប្រឹក្សា ក្រសួងការពារជាតិ

៤- លោក **អ៊ុ ឈាន** ជាប្រតិភូរាជរដ្ឋាភិបាល ប្រចាំក្រុងប៉ៃលិន

* **ថ្នាក់ឧត្តមសេនីយ៍ត្រី :**

១- លោក **ឈឹម សេង** ជាទីប្រឹក្សា ក្រសួងការពារជាតិ

២- លោក **យ៉ឹម ធិត្យ** ជាទីប្រឹក្សា ក្រសួងការពារជាតិ

៣- លោក **ស៊ុ ម៉េត** ជាទីប្រឹក្សា ក្រសួងការពារជាតិ

៤- លោក **ឡាំ ស៊ុ** ជាអភិបាលរងខេត្ត

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និងជាសហអគ្គមេបញ្ជាការកងកំលាំងប្រដាប់អាវុធជាតិកម្ពុជា ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៩៧

តួនាទីព្រះមហាក្សត្រ ព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * * * *

ព្រះរាជក្រឹត្យ នស/រកត/០៤៩៧/១៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទាំងពីរ និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងមុខងារ និងប្រគល់ឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយទាហានជាន់ខ្ពស់ដែលមានរាយនាម ដូចខាងក្រោមនេះ ៖

១- លោក **ឡុង ថែម** មេបញ្ជាការរង យោធភូមិភាគទី ៤

២- លោក **ហ៊ុំ ពុន** មេបញ្ជាការរង យោធភូមិភាគទី ៥

៣- លោក **សុខ សាត** មេបញ្ជាការរង យោធភូមិភាគទី ៥

៤- លោក **ម៉ែន ទ្វីយ** មេបញ្ជាការ កងពលធំលេខ ១៥

៥- លោក **អ៊ិន ផាន** មេបញ្ជាការ កងពលធំលេខ ១៦

៦- លោក **ពៀម គន់** មេបញ្ជាការ កងពលធំលេខ ១៧

៧- លោក **សុខ ឈាន** មេបញ្ជាការ កងពលធំលេខ ១៨

៨- លោក **ស្រី សុបិន្ត** មេបញ្ជាការ កងពលធំលេខ ១៩

៩- លោក **ជា គួនគិរម្យ** មេបញ្ជាការ កងពលធំលេខ ២០

១០- លោក **ឆឹង ផុន** មេបញ្ជាការ កងពលធំលេខ ២១

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និងជាសហអគ្គមេបញ្ជាការកងកំលាំងប្រដាប់អាវុធជាតិកម្ពុជា ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសប្តាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

II- រាជរដ្ឋាភិបាល

១—អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ៤២ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង អភិបាលរងខេត្ត-ក្រុង

– តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១: – តែងតាំងលោក **ឃឹម សិលា** ជាអភិបាលរងទី ១ ខេត្តព្រះវិហារ

– តែងតាំងលោក **ឡុង សុវណ្ណ** ជាអភិបាលរងទី ២ ខេត្តព្រះវិហារ

– តែងតាំងលោក **ស៊ុំ អ៊ាន** ជាអភិបាលរងទី ៣ ខេត្តព្រះវិហារ

– តែងតាំងលោក **ប៉ាល់ សំអឿន** ជាអភិបាលរងទី ១ ខេត្តឧត្ដរមានជ័យ

– តែងតាំងលោកឧត្ដមសេនីយ៍ត្រី **ឃុត សំអាន់** ជាអភិបាលរងទី ២ ខេត្តឧត្ដរមានជ័យ

– តែងតាំងលោក **ឃឹម ឌិន** ជាអភិបាលរងទី ៣ ខេត្តឧត្ដរមានជ័យ

– តែងតាំងលោកឧត្ដមសេនីយ៍ **មាឌ្យ យុទ្ធ** ជាអភិបាលរងទី ២ ខេត្តសៀមរាប

– តែងតាំងលោក **សាយ ហាក់** ជាអភិបាលរងទី ៣ ខេត្តកោះកុង ជំនួសលោក **វណ្ណ គីរត្ន័** ដែលត្រូវផ្លាស់មកក្រសួងមហាផ្ទៃ ។

មាត្រា ២: – សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង អស់លោកដែលមានឈ្មោះក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ថលេខា និងត្រា
នរោត្ដម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
ហ៊ុន សែន

* * * * *

III- ការងារបណ្ដាក្រសួង

១– ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសអន្តរក្រសួង

រាជធានីភ្នំពេញថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១២៩ សហវ.មប្រក

ស្ដីពីការបង្កើតគណនេយ្យប្រចាំការ

នៅក្រសួងមហាផ្ទៃផ្នែករដ្ឋបាល

***

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តនីតិវិធីបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តនីតិវិធីបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការប្រព្រឹត្តទៅនៃរដ្ឋទេយ្យបុរេប្រទាន
- បានឃើញតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន

សម្រេច

ប្រការ ១ : ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទាននៅក្រសួងមហាផ្ទៃ ដើម្បីទូទាត់ចំណាយនានាផ្សេងៗ ដែលមានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អន.ក្រ បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីអំពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។

ចំនួនទឹកប្រាក់ជាអតិបរមានៃចំណាយដែលអនុញ្ញាតអោយរដ្ឋទេយ្យបុរេប្រទានធ្វើការទូទាត់ត្រូវកំណត់ដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ២ : ចំនួនទឹកប្រាក់នៃរដ្ឋទេយ្យបុរេប្រទានត្រូវបានកំណត់ត្រឹមចំនួន ៥៩.០០០.០០០រ០០ ។

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	ទេសរដ្ឋមន្ត្រី
ហត្ថលេខា និងត្រា	រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
	ហត្ថលេខា
ស ខេង **យូ ហុកគ្រី**	**គាត ឈន់**

* * * * *

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
នាយកដ្ឋានហិរញ្ញវត្ថុ

តារាងគំរោងចំណាយថវិកាបុរេប្រទានឆ្នាំ ១៩៩៧
ក្រសួងមហាផ្ទៃ រដ្ឋបាលទូទៅ

ជំពូក ប្រការ កថា-ភិក្ខុខ័ណ្ឌ	បរិយាយ	ផែនការអនុវត្ត	បុរេប្រទានស្នើសុំ	បុរេប្រទានផ្តល់អោយ	ផ្សេងៗ
១១-០១-០១-០២	ការរៀបចំ និងថែទាំ	៤០០.០០០.០០០:០០	២០០.០០០.០០០:០០	១៥.០០០.០០០:០០	
១១-០១-០២	ចលនវត្ថុ និងសំភារៈ	២០០.០០០.០០០:០០	១០០.០០០.០០០:០០	៣.៥០០.០០០:០០	
១១-០១-០៤	ក្រដាសបោះពុម្ព និងសំភារៈការិយាល័យ	២៤០.០០០.០០០:០០	១៥០.០០០.០០០:០០	៦.០០០.០០០:០០	
១១-០១-០៥	សៀវភៅមើល និងឯកសារ	៣០.០០០.០០០:០០	៣០.០០០.០០០:០០	១.១២៥.០០០:០០	
១១-០១-០៦	សន្និសីទ និងប្រជុំ	១០០.០០០.០០០:០០	១០០.០០០.០០០:០០	៣.៧៥០.០០០:០០	
១១-០១-០៧-០១	ការថែទាំ និងដំណើរការ	១០០.០០០.០០០:០០	១០០.០០០.០០០:០០	៣.៧៥០.០០០:០០	
១១-០១-០៧-០៣	សោហ៊ុយជួលថេយន្ត	៥.០០០.០០០:០០	៥.០០០.០០០:០០	១៨៧.៥០០:០០	
១១-០១-០៨-០១	សោហ៊ុយទទួលភ្ញៀវបរទេស	២០.០០០.០០០:០០	២០.០០០.០០០:០០	៧៥០.០០០:០០	
១១-០១-០៨-០២	សោហ៊ុយទទួលភ្ញៀវជាតិ	១០០.០០០.០០០:០០	១០០.០០០.០០០:០០	៣.៧៥០.០០០:០០	
១១-០១-០៩-០១	សោហ៊ុយពិធីបុណ្យប្រពៃណី	៥.០០០.០០០:០០	៥.០០០.០០០:០០	១៨៧.៥០០:០០	
១១-០១-១០	ចំណាយឯកសណ្ឋាន	៥.០៨០.០០០.០០០:០០	៣.០០០.០០០:០០		
១១-០១-១២-០៣	សិក្ខាសាលា ឬកិច្ចប្រជុំ	១០០.០០០.០០០:០០	១០០.០០០.០០០:០០	៣.៧៥០.០០០:០០	
១១-០១-១៤-០៦	ចំណាយសំរាប់អ្នកទោស	២.៦០០.០០០.០០០:០០	១.៨៧២.០០០.០០០:០០	៥.០០០.០០០:០០	
១១-០១-៩៩	ចំណាយផ្សេងៗលើការប្រើប្រាស់សម្ភារៈនិងសេវាទានា	៤០.០០០.០០០:០០	១០.០០០.០០០:០០	១.៥០០.០០០:០០	
១១-០២-០១-០១	សោហ៊ុយដឹកជញ្ជូនក្នុងប្រទេស	៣០.០០០.០០០:០០	៣០.០០០.០០០:០០	១.១២៥.០០០:០០	
១១-០២-០១-០២	សោហ៊ុយបេសកកម្ម	៣០.០០០.០០០:០០	៣០.០០០.០០០:០០	១.១២៥.០០០:០០	
១១-០២-០១-០៣	សោហ៊ុយស្នាក់នៅ	៤០.០០០.០០០:០០	៤០.០០០.០០០:០០	១.៥០០.០០០:០០	

១១-០២-០២-០១	សោហ៊ុយដឹកជញ្ជូនក្រៅប្រទេស	៣០.០០០.០០០៖០០	៣០.០០០.០០០៖០០		
១១-០២-០២-០២	សោហ៊ុយបេសកកម្ម	២០.០០០.០០០៖០០	២០.០០០.០០០៖០០		
១១-០២-០២-០៣	សោហ៊ុយស្នាក់នៅ	២០.០០០.០០០៖០០	២០.០០០.០០០៖០០		
១-០២-០២-០៤	សោហ៊ុយផ្សេងៗ	២០.០០០.០០០៖០០	២០.០០០.០០០៖០០		
	សរុបជំពូក ១១	៥.២១០.០០០.០០០៖០០	២.៩៨៥.០០០.០០០៖០០	៥៥.០០០.០០០៖០០	
៣១-០១-០២-០១	ឧបត្ថម្ភឃុំ និងសហគមន៍	១៥០.០០០.០០០៖០០	១៥០.០០០.០០០៖០០		
	សរុបរួម (១១ និង ៣១)	៥.៣៦០.០០០.០០០៖០០	៣.១៣៥.០០០.០០០៖០០	៥៥.០០០.០០០៖០០	

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ

ហត្ថលេខា

មោឌ សុផល

រាជធានីភ្នំពេញថ្ងៃ ០៩ ខែ មេសា ឆ្នាំ ១៩៩៧

លេខ ១៣១ សហ.រម.ប្រក

ស្តីពី

ការបង្កើត គណនេយ្យបុរេប្រទាន

នៅរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

* * * * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យ លេខ នស-រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១ ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃ គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.រ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តនីបទ បញ្ញត្តិទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋទេយ្យបុរេ ប្រទាន
- បានឃើញតម្រូវការចាំបាច់ នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទានបន្ថែម នៅរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីទូទាត់ ចំណាយទាំងឡាយដែលមានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទៅនៃគណនេយ្យសាធារណៈ ។

ចំនួនទឹកប្រាក់ជាអតិបរមា នៃចំណាយដែលអនុញ្ញាតអោយរដ្ឋទេយ្យករបុរេប្រទានធ្វើការទូទាត់ត្រូវ កំណត់ដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ២ : ចំនួនទឹកប្រាក់នៃរដ្ឋទេយ្យបុរេប្រទានត្រូវកំណត់បន្ថែមចំនួន ៤២.៧៥០.០០០រៀល លើទឹកប្រាក់ចំនួន ១៣.០០០.០០០៛០០ ដែលបានកំណត់តាមប្រកាសអន្តរក្រសួង ស្តីពីការបង្កើតរដ្ឋទេយ្យបុរេប្រទាននៅ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល លេខ ៦៦៨ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារជាតិ ឧាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានភារកិច្ចទទួលបន្ទុក អនុវត្តតាម ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយក	ហត្ថលេខា និង ត្រា
ហត្ថលេខានិងត្រា	**គាត ឈន់**
កែវ សាវិន	

* * * * *

២–ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៩៧

ប្រកាស

ប្រកាសលេខ ១២៥ ពណគន. ប្រក

ស្តីពី

ការប្រគល់ទីតាំងដីយានដ្ឋាន នៅសង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក ក្រុងភ្នំពេញ

រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញកំណត់ហេតុប្រគល់_ទទួលទីតាំងដីយានដ្ឋាន នៅសង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក ក្រុងភ្នំពេញ ចុះថ្ងៃទី ០៣_៤_៩៧ ។

សំរេច

ប្រការ ១ : ប្រគល់ការគ្រប់គ្រងទីតាំងយានដ្ឋាន ដែលមានផ្ទៃដីសរុប ៣.២៤៩ m² មានបណ្តោយ ៥៧ m ទទឹង ៥៧ m ស្ថិតនៅផ្លូវលេខ ២៣០ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក ជូនទៅលោក **ឈិត មាន** ជាអ្នកគ្រប់គ្រងផ្ទាល់ ដោយផ្តាច់ចេញពីការគ្រប់គ្រងរបស់ក្រុមហ៊ុនកសិកម្ម_រុក្ខផល ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រការ ២ : លោក **ឈិត មាន** ត្រូវគោរព និង អនុវត្តអោយបាននូវរាល់ប្រការផ្សេងៗនៃច្បាប់របស់រដ្ឋដើម្បី ធានាដល់សុវត្ថិភាព និង បរិដ្ឋានសង្គម ។

ប្រការ ៣ ៈ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានក្រុមហ៊ុនកសិផល_រុក្ខផល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

* * * * *

៣—និស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

ប្រកាសលេខ ៣៦៧ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សេខ លី** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៧៨១០៤ ក.ព ចុះថ្ងៃទី ១០_៨_៩០ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦៥ អឺ១ ផ្លូវលេខ ២៦៨ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតឥដ្ឋការ៉ូនៅក្នុងទីតាំង ផ្ទះ លេខ ២៧ ផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកង ៣ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៣៦៨ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយសិប្បកម្មផលិតឥដ្ឋ-ក្បឿង ដែលមានអ្នកស្រី **ឌូ ស៊ុះស្មៀន** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៦០៣៧៩ ភ.ព ចុះថ្ងៃទី ១៤-១០-៨៨ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិដើមគរ ឃុំដើមមៀន ស្រុកតាខ្មៅ ខេត្តកណ្តាល បន្តដំណើរការសិប្បកម្ម ផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ : ៣៧២ ឧក.ប្រក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឡេង ប៊ុនឃុន** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣៥១៣២៩ ភ.ព ចុះថ្ងៃទី ០៣-៣-៩៤ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៩៥ អឺ០ ផ្លូវ លេខ ១៣៦ សង្កាត់ ផ្សារកណ្តាលទី ២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បើកដំណើរការ ឧស្សាហកម្មតូចផលិតសំភារៈប្រើប្រាស់អំពីប្លាស្ទិក នៅក្នុងទីតាំង ផ្ទះលេខ ១៦៨៣ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ : ៣៧៣ ផក.ប្រក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ចុង ឃាត់** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២១៩៩៩ ភ.ព ចុះថ្ងៃទី ២៧_១២_៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦៨ អឺ០ ផ្លូវ លេខ ១៤៨ សង្កាត់ ផ្សារកណ្តាលទី ២ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការរោងជាងក្រឡឹងដែក នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ : ៣៧៤ ផក.ប្រក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយឧស្សាហកម្មតូចផលិតឧស្ម័នអុកស៊ីហ្សែន និង អាសេទីឡែនដែលមានលោក **ចាន់ គាយ** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩១៦១៩ ភ.ព ចុះថ្ងៃទី ២៥_៣_៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៦៦ អឺ០ ផ្លូវ លេខ ២១៧ សង្កាត់ អូរឬស្សីទី ៣ ខណ្ឌ ៧មករា រាជធានី ភ្នំពេញ ជាប្រធានបើកដំណើរការ ឧស្សាហកម្មតូចផលិតឧស្ម័នអុកស៊ីហ្សែន និង អាសេទីឡែន នៅក្នុងដីឡូត៍ថ្មី ផ្លូវ រោងចក្រកែវ សង្កាត់ ដង្កោ ខណ្ឌ ដង្កោ រាជធានី ភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ : ៣៧៥ ឧក.ប្រក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឆេស ឡេត** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៥២១៧៩៤ ក.ច ចុះថ្ងៃទី ២៨_៤_៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិលេខ ២ ឃុំ តងជ័យ ស្រុក អូរាំងឪ ខេត្តកំពង់ចាម បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឆេស ឡូត** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ : ៣៧៦ ឧក.ប្រក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ែន សាន** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៧៨១១៦ ភ.ព ចុះថ្ងៃទី ០៨_០២_៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៧៨៩ វិថី ព្រះមុនីវង្ស ក្រុមទី ១០ សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូចផលិតស្បៀវភៅសរសេរ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ : ៣៧៧ ឧក.ប្រក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ទង់ ឈារិន** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៩៨៨៩១ ភ.ព ចុះថ្ងៃទី ១១_៣_៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១១៣ អឹ០ ផ្លូវ លេខ ១៣០ សង្កាត់ ផ្សារចាស់ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ ចំនួនពីរគ្រឿង កំលាំង ៨០ សេះ និង ១២០សេះ នៅក្នុងទីតាំង ដីឡូត៍គ្មានលេខ ផ្លូវ ចំការដូង ភូមិម៉ល សង្កាត់ដង្កោ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ទង់ ឈារិន** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ ១ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ : ៣៧៨ ឧក.ប្រក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ គង់** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០៦២៦៨ ភ.ព ចុះថ្ងៃទី ២២_៣_៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤៨០ អឺ០ ផ្លូវ កម្ពុជាក្រោម សង្កាត់ មិត្តភាព ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ បើកដំណើរការ សិប្បកម្មកាត់ដេរសំលៀកបំពាក់ នៅក្នុងទីតាំង ផ្ទះលេខ ២២៣ ផ្លូវលេខ ៣៥៧ ភូមិ ដើមស្លែង សង្កាត់ ផ្សារអំពៅទី២ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

*****

ប្រកាសលេខ : ៣៨០ ឧក.ប្រក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឈាង ម៉េង** ជនជាតិ ខ្មែរ សញ្ញាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៣៥២៩០ ភ.ព ចុះថ្ងៃទី ១៣_០១_៩៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥៧ ផ្លូវ លេខ ៩៥ សង្កាត់ បឹងកេងកងទី ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការ សិប្បកម្មតៅថ្មេ ទឹកត្រី និង ផលិតទឹកក្រួងនៅក្នុងតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឈាង ម៉េង** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើផលិតផលចំនួន ៣ មុខ គឺទឹកត្រីកំពតលេខ ១ ទឹកត្រីពិសេសលេខ ១ និង ទឹកក្រួង «រូបឆ្មាំង» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ិត ប្រាំង

*****

ប្រកាសលេខ ៣៨២ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុនផលិតម្សៅដំឡូងមី ចំកាត់ (FLOUR MANUFACTURING CO.,LTD) តំណាងដោយលោក **កែវ ឧត្តម** ជនជាតិ ខ្មែរ ភេទប្រុស អាយុ ៤៣ឆ្នាំ អាស័យដ្ឋានផ្ទះលេខ ៣១ ផ្លូវលេខ ៣៥០ សង្កាត់ ទួលស្វាយព្រៃទី ១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ កាន់ អត្តសញ្ញាណប័ណ្ណលេខ ២២៦៤០០ ភព ចុះថ្ងៃទី ២៥.៤.១៩៨៩ «បង្កើតរោងចក្រផលិតម្សៅ ដំឡូងមី» ដែលមានឈ្មោះ «រោងចក្រ ម្សៅដំឡូងមី **កែវ ឧត្តម**» មានទីតាំងស្ថិតនៅ ភូមិទួលដំណាក់ ឃុំ ស្រឡៅ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

ប្រការ ២ : ការសាងសង់និងរៀបចំគ្រឿងចក្រ ត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានសំរេចក្នុងរយៈពេល ០៦ ខែដោយរាប់ បញ្ចូលទាំងរយៈពេល ដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន អនាម័យ និង គុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវផលិតផល «ម្សៅដំឡូងមី» ទៅតាមគំរូ និង ផ្លាកសញ្ញា ដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសផ្ទុយនឹងប្រការណាមួយដែលបានចែងខាង លើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ៣៨៣ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ស៊ីភី ខេមបូឌា (C.P.CAMBODIA Co.,LTD) តំណាងដោយលោក ANAN ATHI GAPANICH ជនជាតិថៃ ភេទប្រុស អាយុ ៤៥ ឆ្នាំ អាស័យដ្ឋាន ១១៣ CP TOWER, SILOM ROAD, BANGKOK,

THAIAND ភ្ជាប់លិខិតឆ្លងដែនលេខ N072772 ចុះថ្ងៃទី ០៣.៣.៩៣ «បង្កើតរោងចក្រផលិតចំណីសត្វ» ដែលមានឈ្មោះថា «រោងចក្រផលិតចំណីសត្វ ស៊ីភី ខេមបូឌា» មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ ភូមិស្វាយជ្រុំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល ។

ប្រការ ២ : ការសាងសង់និងរៀបចំគ្រឿងចក្រ ត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានរួចក្នុងរយៈពេល ១២ ខែ ដោយរាប់បញ្ចូលទាំងរយៈពេល ដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវ «ចំណីសត្វ» ទៅតាមគំរូនិងផ្លាកសញ្ញា ដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * * * *

ប្រកាសលេខ ៣៨៤ ឧក.ប្រក ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **គ្រុយ ឈៀង** ជាម្ចាស់រោងម៉ាស៊ីនកិនស្រូវ ដែលមានទីតាំងភូមិផ្អែកក្ងួន ឃុំគោកឃ្មុំ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ផ្ទេរភារកិច្ចគ្រប់គ្រងលើម៉ាស៊ីនកិនស្រូវនេះជូន លោក យូ សាមេត វិញ ។

ប្រការ ២ : ទទួលស្គាល់លោក **យូ សាមេត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧០៧៣២ ប.ប ចុះថ្ងៃទី ០៣-៩-៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ២០ ឧសភា ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ជាប្រធានរោងម៉ាស៊ីនកិនស្រូវ ដែលទីតាំងដូចមានចែងក្នុង ប្រការ ១ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៣៨៥ ជក.ប្រក ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឆូ ឃួត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៥៥៦៩ ក.ព ចុះថ្ងៃទី ២៤-០១-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២០ បេអឺ០ ផ្លូវលេខ ៤១០ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតនំផ្អែម យីហោ «សេង ហួត» នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ពូ សុធីរៈ

* * * * *

៤—ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៧

ប្រកាសលេខ : ០៩៩/៩៧ ពម.ប្រក

* * * * *

រដ្ឋមន្ត្រីក្រសួងពតិមាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១_១១
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤_០១_៩៦ ស្តីពីការបង្កើតក្រសួងពតិមាន
- យោងលិខិតអនុញ្ញាតអោយបើកអាជីវកម្មរោងពុម្ព «រស្មីអង្គរ» លេខ ០១៦/៩៥ ព.ម ចុះថ្ងៃទី ០៦_០១_៩៥ របស់ក្រសួងពតិមាន
- យោងលិខិតសំណើសុំផ្ទេរសិទ្ធិគ្រប់គ្រងអាជីវកម្មរោងពុម្ព «រស្មីអង្គរ» ចុះថ្ងៃទី ០១_៤_៩៧

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក ហ៊ិ មៀង ស្ថិតនៅផ្ទះលេខ ៣៨.៤០ អឺស៊ើរ ផ្លូវលេខ ១៣៩ សង្កាត់វាលវង់ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ បន្តបើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ «រស្មីអង្គរ » ស្ថិតនៅទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របតាមទំនៀមទំលាប់ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាម៉ីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃក្រសួងពតិមាន និង ប្រធានមន្ទីរពតិមានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ១៩៩៧

ប្រកាសលេខ : ១០១/៩៧ ពម.ប្រក

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ករុណា ចុះថ្ងៃទី ០១_១១_៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០១៩៦_១៤ នសរកម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងសំណើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មទូរទស្សន៍រលកធាតុអាកាសប្រព័ន្ធ MMDS របស់លោក **ខឹម សារិទ្ធិ** ចុះថ្ងៃទី ៣០_៣_៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ខឹម សារិទ្ធិ** ស្ថិតនៅផ្ទះលេខ ១១០ ផ្លូវ ៥១ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ បើកអាជីវកម្មទូរទស្សន៍រលកធាតុអាកាសប្រព័ន្ធ MMDS សំរាប់បន្តជាវអោយអតិថិជននៅតាមខេត្ត-ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ស្ថានីយ៍ទូរទស្សន៍នេះ ត្រូវគោរពតាមកិច្ចសន្យា និងច្បាប់បញ្ញត្តិបទបញ្ជា ឬសេចក្តីណែនាំខាងផ្នែកសោតទស្សន៍ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស ដូចមានចែងក្នុងប្រការ ២ សាមីខ្លួននឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយកដ្ឋានទូរទស្សន៍កម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ_សោតទស្សន៍នៃក្រសួងពត៌មាន ប្រធានមន្ទីរពត៌មានតាមខេត្ត_ក្រុង និងអាជ្ញាធរដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

៥—ទីស្ដីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាសរួម

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៧

ប្រកាសរួមលេខ : ១៤៧ ប្រក.សក

ស្ដីពី

ពន្ធលើការធ្វើដំណើរនៅព្រលានយន្តហោះពោធិ៍ចិនតុង

* * * * *

អន្តរក្រសួង

សាធារណការ និងដឹកជញ្ជូន និង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១_១១_១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១១០_៩៤/៩០ ចុះថ្ងៃទី ៣១-១០-៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

- យោងលិខិតលេខ ២១៧ សជណ ចុះថ្ងៃទី ០៤-៣-១៩៩៧ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

សំរេច

ប្រការ ១ : កំណត់ថ្លៃពន្ធលើការធ្វើដំណើរនៅព្រលានយន្តហោះ អន្តរជាតិពោធិចិនតុង ចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៧ តទៅតាមអត្រាដូចខាងក្រោមនេះ :

ចំពោះអ្នកដំណើរជនជាតិបរទេស :

ក-ថ្លៃសេវាលើអ្នកដំណើរ លើការហោះហើរអន្តរជាតិ ២០$ (ម្ភៃ) ដុល្លារអាមេរិក

ខ-ថ្លៃសេវាលើអ្នកដំណើរ លើការហោះហើរក្នុងស្រុក ១០$ (ដប់) ដុល្លារអាមេរិក

ចំពោះអ្នកដំណើរជាតិខ្មែរ ដែលរស់នៅក្នុងប្រទេសកម្ពុជា :

ក-ថ្លៃសេវាលើអ្នកដំណើរ លើការហោះហើរអន្តរជាតិ ១៥$ (ដប់ប្រាំ) ដុល្លារអាមេរិក

ខ-ថ្លៃសេវាលើអ្នកដំណើរ លើការហោះហើរក្នុងខេត្តសៀមរាប ៥$ (ប្រាំ) ដុល្លារអាមេរិក

គ-ថ្លៃសេវាលើអ្នកដំណើរ លើការហោះហើរក្នុងខេត្តផ្សេងៗទៀត៤$(បួន) ដុល្លារអាមេរិក

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានន័យផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : លោកនាយកខុទ្ទកាល័យ លោកអគ្គនាយកនៃក្រសួងទាំងពីរ ត្រូវទទួលបន្ទុកតាមភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ។

ទេសរដ្ឋមន្ត្រី	ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន
ហត្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
គាត ឈន់	**វុំង ស៊ៀត**

* * * * *

៦—ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១—សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ១៥៩ សសរ.កសក

ស្តីពី

ការលក់ឧបករណ៍សំភារៈកសិកម្ម

* * * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលេខ នស.រកត ១០៩៤_៨៣ ចុះថ្ងៃទី ២៤ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ចរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩១ របស់គណៈរដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងថ្លៃ
- បានឃើញការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : កំណត់ថ្លៃលក់ឧបករណ៍សំភារៈកសិកម្មជូនប្រជាជន តាមថ្លៃដូចខាងក្រោម :

- ជី ១៦_២០_០ : ៣៣.០០០ រៀល / បាវ ទំងន់ ៥០ គ.ក្រ
- ម៉ាស៊ីនកិនស្រូវ : ៨.៦០៦.១០០ រៀល / គ្រឿង ។

- ម៉ាស៊ីនច្រូតស្រូវ : ៤.៦០៦.២០០ រៀល /គ្រឿង
- ម៉ាស៊ីនបោកស្រូវ : ៤.៣១៩.២០០ រៀល /គ្រឿង
- ម៉ាស៊ីនបូមទឹកប្រភេទ KUBOTA មានកំលាំងសេះ ១២ HP : ៣.៩៨៣.៩០០រៀល/គ្រឿង
- ម៉ាស៊ីនបូមទឹកប្រភេទ MITSUBISHI មានកំលាំងសេះ ១១ HP : ៤.៥១៩.៣០០រៀល/គ្រឿង
- ម៉ាស៊ីនបូមទឹកប្រភេទ MITSUBISHI មានកំលាំងសេះ ០៩HP : ៣.៩៧៩.៨០០រៀល/គ្រឿង
- រថយន្តម៉ាក NISSAN ចំណុះផ្ទុក ៨តោន : ៦៦.០០០.០០០ រៀល/គ្រឿង

ប្រការ ២ : គោលការណ៍នៃការទូទាត់តំលៃឧបករណ៍សំភារៈកសិកម្ម មានដូចខាងក្រោម :

- ចំពោះជី ១៦_២០_០ : ត្រូវធ្វើការទូទាត់រយៈពេល ១ឆ្នាំ គ្រប់ចំនួននៅក្រោយពេលរដូវប្រមូលផល
